# ព្រះយេស៊ូវគ្រីស្ទអញ្ជើញយើងឲ្យរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ដោយ . . .

### . . . ការចាកចេញពីបាប៊ីឡូន ( សេចក្ដីទុច្ចរិត ) ( សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣៣:៤–៥, ៧, ១២–១៤ ) ។

ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ ដែលកាលនោះនៅក្នុងគណៈប្រធានទីមួយបានបង្រៀន ៖



ទីក្រុងបាប៊ីឡូនពីបុរាណត្រូវបានវិនាសហើយ ។ ភាពរុងរឿងរបស់វាបានរលត់បាត់ហើយ ។ ប៉ុន្តែភាពខាងលោកិយ និងសេចក្ដីទុច្ចរិតរបស់វាបន្តនៅមាន ។ ឥឡូវជាការទទួលខុសត្រូវរបស់យើងដើម្បីរស់នៅជាអ្នកជឿក្នុងពិភពលោកឥតជំនឿ ។ . . . យើងនឹងត្រូវនៅស្ងប់ស្ងៀមក្រោមសម្ពាធពីមិត្តភក្តិ ពុំចាំបាច់ត្រូវមានការសរសើរពីទំនោរប្រជាប្រិយភាព ឬព្យាការីក្លែងក្លាយទេ កុំខ្វល់នឹងការរិះគន់ពីពួកមនុស្សអាក្រក់ ទប់ទល់នឹងការល្បួងនៃមេអាក្រក់ ហើយយកឈ្នះលើភាពខ្ជិលច្រអូសផ្ទាល់ខ្លួនរបស់យើង ។ ( ឌៀថើរ អេហ្វ អុជដូហ្វ « Be Not Afraid, Only Believe » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ៧៧–៧៨ )

### . . . ប្រមូលសាសន៍អ៊ីស្រាអែល ( សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣៣:៤, ៧–៩, ៣៧–៣៨ ) ។

ប្រធាន រ័សុល អិម ណិលសុន បានរំឭកយើងថា ៖



*រាល់ពេល* ដែលប្អូនៗធ្វើ *អ្វីមួយ* ដើម្បីជួយ *នរណាម្នាក់*—ទាំងសងខាងនៃវាំងនន—ឲ្យបោះជំហានទៅធ្វើសេចក្ដីសញ្ញាជាមួយនឹងព្រះ ហើយទទួលពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹក និងពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធដ៏សំខាន់របស់ពួកគេ នោះអ្នកកំពុងជួយប្រមូលសាសន៍អ៊ីស្រាអែលហើយ ។ វាជាការណ៍ដ៏សាមញ្ញណាស់ ។ ( រ័សុល អិម ណិលសុន នៅក្នុង « សង្ឃឹមអ៊ីស្រាអែល » [ ការប្រជុំធម្មនិដ្ឋានទូទាំងពិភពលោកសម្រាប់យុវវ័យថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៨ ] នៅលើគេហទំព័រ broadcasts.ChurchofJesusChrist.org )

### . . . ការប្រែចិត្ត និងការត្រូវបានញែកចេញជាបរិសុទ្ធតាមរយៈព្រះយេស៊ូវគ្រីស្ទ ( សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣៣:៥, ១៦, ៣៤–៣៥, ៦២ ) ។

ស៊ីស្ទើរ ខារ៉ុល អេហ្វ ម៉ាកខន់ឃី អតីតទីប្រឹក្សាក្នុងគណៈប្រធានយុវនារីទូទៅបានបង្រៀន ៖



ដោយការមានសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងនៅលើដង្វាយធួនរបស់ទ្រង់ នោះយើងអាចបានស្អាតស្អំ គ្មានស្នាមប្រឡាក់ខណៈដែលយើងមិនបណ្ដោយខ្លួនទៅក្នុងសេចក្ដីអាក្រក់ ហើយប្រែចិត្តដោយស្មោះ ។ យើងបានទទួលពិធីបុណ្យជ្រមុជទឹកសម្រាប់ការផ្ដាច់បាប ។ ព្រលឹងយើងត្រូវបានធ្វើឲ្យបរិសុទ្ធនៅពេលយើងទទួលព្រះវិញ្ញាណបរិសុទ្ធដោយស្មោះសរ ។ រាល់សប្ដាហ៍យើងទទួលពិធីបរិសុទ្ធនៃពិធីសាក្រាម៉ង់ ។ ពេលយើងមានស្មារតីប្រែចិត្តដោយមានបំណងដ៏ស្មោះដើម្បីមានភាពសុចរិត នោះយើងចុះសេចក្ដីសញ្ញាថាយើងនឹងមានឆន្ទៈលើកដាក់ព្រះនាមនៃព្រះគ្រីស្ទមកលើខ្លួនយើង ចងចាំទ្រង់ ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយដើម្បីយើងអាចមានព្រះវិញ្ញាណរបស់ទ្រង់គង់ជាមួយយើងជានិច្ច ។ ( ខារ៉ុល អេហ្វ ម៉ាកខន់ឃី « The Beauty of Holiness » *Liahona* ខែ ឧសភា ឆ្នាំ ២០១៧ ទំព័រ ១០ )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_461-1